នស/រកត/០១២៤/ ០០១

# ព្រះរាជក្រឹត្យ
## ស្ដីពី
## ការកែសម្រួលព្រះរាជក្រឹត្យស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ .-**

មាត្រា២ មាត្រា៣ មាត្រា៧ និងអង្គការលេខនៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា២ .- ថ្មី**

ក.ជ.ក. មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រី | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |



https://www.moj.gov.kh/kh/law-regular

- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប អនុប្រធាន
- អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងផែនការ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប សមាជិក
- តំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ១រូប សមាជិក
- តំណាងសមាគមជាតិកាកបាទក្រហមកម្ពុជា ១រូប សមាជិក
- តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ១រូប សមាជិក
- តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ១រូប សមាជិក
- អគ្គលេខាធិការ **ក.ជ.ក.** សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងរបស់ **ក.ជ.ក.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។



https://www.moj.gov.kh/kh/law-regular

**ក.ជ.ក.** អាចមានសមាសភាពបន្ថែមជាអនុប្រធាននិងសមាជិក ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។ សមាសភាពបន្ថែមនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ ._ ថ្មី**

**ក.ជ.ក.** មានភារកិច្ចដូចតទៅ៖

- ពិគ្រោះយោបល់និងសម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាកុមារ
- ចូលរួមពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកុមារ
- រៀបចំគោលនយោបាយ ផែនការកម្មវិធី និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍ដល់កុមារមានជាអាទិ៍ ការគោរពនិងការអនុវត្តសិទ្ធិកុមារ ការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារ ការប្រឆាំងនឹងអំពើហិង្សា ការទប់ស្កាត់ការលុបបំបាត់ ការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ និងការប្រឆាំងនឹងការជួញដូរគ្រឿងញៀន
- ផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតូបករណ៍អន្តរជាតិផ្សេងទៀតដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព
- ស្រាវជ្រាវនិងជូនព័ត៌មានស្តីពីសេចក្តីត្រូវការនិងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងកុមារកម្ពុជាជូនរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការនានាដែលមានសមត្ថកិច្ច
- អនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិនិងអនុសាសន៍របស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់សិទ្ធិនិងឧត្តមប្រយោជន៍កុមារ
- លើកកម្ពស់កិច្ចការពារកុមារតាមគ្រប់រូបភាពនិងទម្រង់ទាំងអស់
- ធ្វើទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដែលមានការងារប្រហាក់ប្រហែលគ្នា ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធ និងទស្សនៈរីកចម្រើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អស្ថានភាពកុមារ
- ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតូបករណ៍អន្តរជាតិផ្សេងទៀតដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារនៅកម្ពុជា និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការនិងបញ្ហាទាំងឡាយដែលជានាឧត្តមប្រយោជន៍របស់កុមារ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតូបករណ៍អន្តរជាតិផ្សេងទៀតដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៧ ._ ថ្មី**

**ក.ជ.ក.** មានរូបសញ្ញានិងត្រាដោយឡែក ដើម្បីបំពេញការងាររបស់ខ្លួន ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ជ.ក.**។



https://www.moj.gov.kh/kh/law-regular

**អគ្គការលេខថ្មីនៃចនាសម្ព័ន្ធរបស់ ក.ជ.ក. ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។**

**មាត្រាពីរ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី ._**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ ១៨ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០២៤

ពរល.២៤០១.០០១

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ជា សុមេធី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**



https://www.moj.gov.kh/kh/law-regular

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/០៣២៤/០០៣ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២៤
ស្ដីពីការកែសម្រួលព្រះរាជក្រឹត្យស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# អង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ




ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

https://www.moj.gov.kh/kh/law-regular